

EAST-WEST SEED

# ការគ្របរង

## ការណែនាំអំពីបច្ចេកទេស

## • ការរៀបចំដី



ខ្មែរ (KHMER)



ភ្ជួររាស់ដី ២ ទៅ ៣ដង ជាមួយម៉ាស៊ីនភ្ជួរដី ឬនង្គ័លគោ






រៀបចំលើករង និងដាក់ជីទ្រាប់បាតដោយ ទឹកស្អាត ប្រើជីគីមី លាយជាមួយជីលាមកសត្វពុកផុយ



កំពស់រង



យកចេញ ឬវាយបំបែកដុំដីធំៗ ដើម្បីការពារខ្យល់ក្តៅ នៅពេលគ្របកៅស៊ូ

ការគ្របកៅស៊ូប្លាស្ទិកអាចប្រើប្រាស់បាន៣វដ្តដំណាំ ក្នុងករណីការរៀបចំដីបានល្អ

# • ការគ្របកៅស៊ូប្លាស្ទិច



គ្របកៅស៊ូពណ៌ទឹកប្រាក់នៅខាងលើ







» ប្រើជើងជាន់បណ្តឹងជើងកៅស៊ូប្លាស្ទិចគ្របរង
» កុំទាញតឹងពេក ប៉ុន្តែត្រូវប្រាកដថាមិនមានកន្លែងស្តុកខ្យល់នៅក្រោមកៅស៊ូប្លាស្ទិច
» រក្សាកៅស៊ូប្លាស្ទិចដោយប្រើឃ្នាបឬស្សីខ្ទាស់ជើងរង



វាស់ប្រវែងចន្លោះគុម្ព និងចោះរន្ធ
អោយបានរួចរាល់មុនរៀបចំដាំនៅក្នុងថ្ងៃបន្ទាប់





ដាក់ចំបើងគ្របជុំវិញរន្ធដែលចោះ
ដាំកូនដំណាំ ដើម្បីការពារការកើន
ឡើងខ្យល់ក្តៅឆ្លងកាត់ទៅប៉ះ
នឹងកូនដំណាំ











## គុណសម្បត្តិ

» ការពារទឹកភ្លៀង និងដីហាប់ណែន
» កាត់បន្ថយភាពហាប់ដី
» រក្សាសំណើមដី
» កាត់បន្ថយការដាំទឹក
» កាត់បន្ថយការហូរច្រោះដី
» កាត់បន្ថយការសឹករិចរិល
» ទប់ស្កាត់ការលូតលាស់របស់ស្មៅ
» កាត់បន្ថយពពួកសត្វល្អិតជញ្ជក់
» ធ្វើអោយដំណាំលូតលាស់បានល្អ
» អាចប្រើប្រាស់បាន៣វគ្គដំណាំ

## គុណវិបត្តិ

» ត្រូវចំណាយដើមទុនដំបូង
» ការស្រោចស្រពនៅរដូវប្រាំង បើស្រោចតាមចន្លោះផ្លូវដើរគឺមិនសព្វល្អ
» អាចនឹងមានបញ្ហាកើនឡើងនៃពពួកផ្សិត និងបាក់តេរីក្នុងដីក្នុងករណីដែលមានពពួកវារស់នៅរួចហើយ

# • ការផ្លាស់ប្តូរៈ ការប្រើចំបើងគ្របរង



រៀបចំដាក់ចំបើងគ្របរងបានល្អ មានកម្រាស់ ១០ស.ម និងធ្វើការស្រោចទឹក



វែកចំបើងជារណ្តៅ សំរាប់ដាក់ដាំកូនដំណាំ





## គុណសម្បត្តិ

» រក្សាដីអោយមានភាពត្រជាក់ក្នុងរដូវក្តៅ
» រក្សាសំណើមដី
» ការពារការហូរច្រោះដោយទឹកភ្លៀង
» កាត់បន្ថយការបាត់បង់ជី
» កាត់បន្ថយការដុះស្មៅ
» ជួយកែលំអរគុណភាពដី
» កាត់បន្ថយភាពហាប់របស់ដី
» ធ្វើអោយការលូតលាស់រុក្ខជាតិប្រសើរឡើង
» ការពារផ្លែមិនប៉ះផ្ទាល់នឹងដី

## គុណវិបត្តិ

» ក្នុងករណីមានសំណើមខ្លាំង បើចំបើងនៅជាប់ទៅនឹងដើម អាចជាមូលហេតុដែកបង្កអោយរលួយដើម
» អាចជាការទាក់ទាញសត្វកណ្តុរ និងមាន់
» អាចជាការបង្ករអោយមានសត្វល្អិត និងជម្ងឺផ្សេងៗ

**_http://guides.eastwestseed.com_**
មគ្គុទេសក៍បច្ចេកទេសនេះ គឺជាផ្នែកមួយនៃដំណើរការផលិតដោយ *EWSF* *©2017* រក្សាសិទ្ធិថតចំលងដោយ *East-West Seed Foundation* គ្រប់កម្មសិទ្ធិទាំងអស់ត្រូវបានរក្សាទុក។
*Agrochemical recommendations have been developed in cooperation with Wageningen University & Research*